ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០០៤/១៥ ព័ត៌មាន.ទីស្តី

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ទី០៥ ខែ មិថុនា ឆ្នាំ ២០១៥

ថ្ងៃសុក្រទី០៥ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោង ៨ និង ៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។**
**២-បញ្ហាផ្សេងៗ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត ៖

## ១- សេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

រាជរដ្ឋាភិបាល បានទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់អង្គការសង្គមស៊ីវិល ដោយចាត់ទុកជាដៃគូដ៏មានសក្តានុពល និងប្រសិទ្ធភាពក្នុងកិច្ចដំណើរការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការលើកស្ទួយគាំពារគោលការណ៍ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ជាក់ស្តែងចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបាន និងកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចំនួនសរុបប្រមាណ ៥០០០ ក្នុងនោះរួមមានទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

អនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤២ បានបញ្ញត្តិថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ ហើយសិទ្ធិនេះ ត្រូវកំណត់ដោយច្បាប់។ មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានធានាដល់សិទ្ធិរួបរួមគ្នាជាសមាគមរបស់ប្រជាពលរដ្ឋនៃរដ្ឋហត្ថលេខី គឺតម្រូវឲ្យមានច្បាប់មួយជាចាំបាច់ សំដៅ

ផ្តល់សិទ្ធិក្នុងការបង្កើតសមាគម និងសម្រាប់ការពារការអនុវត្តសិទ្ធិនេះកុំឲ្យមានការរំលោភបំពានណាមួយ។

សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ មានគោលបំណង ធានាការពារសិទ្ធិសេរីភាព ក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬ អង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងអាជ្ញាធរសាធារណៈ ក្នុងការអភិវឌ្ឍសង្គមកម្ពុជាលើគ្រប់វិស័យ។

សេចក្តីព្រាងច្បាប់នេះ បានផ្តល់ឋានៈជានីតិបុគ្គល មិនយកផលចំណេញដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកំណត់អំពីសិទ្ធិ កាតព្វកិច្ច និងទទួលបានការការពារពីច្បាប់ ក្នុងការបន្តធ្វើសកម្មភាព ឬសុំបង្កើតថ្មី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅពេលសេចក្តីព្រាងច្បាប់នេះ ចូលជាធរមាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលតំកល់សំណុំលិខិតនៅក្រសួងមហាផ្ទៃ នឹងទទួលបានជាស្វ័យប្រវត្តិ នូវឋានៈជានីតិបុគ្គល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ក៏ត្រូវចាត់ទុកថា បានចុះអនុស្សរណៈស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈផងដែរ។

សេចក្តីព្រាងច្បាប់នេះ មានចំនួន ៩ជំពូក និង ៣៩មាត្រា មានវិសាលភាពអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិច្បាប់ដោយឡែកដែលចែងពីនេះ។

**២-បញ្ហាផ្សេងៗ**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានសំដែងសេចក្តីសោមនស្សរីករាយចំពោះការវិវត្តរីកចំរើនលើវិស័យកីឡានៅកម្ពុជា ពិសេស កីឡាបាល់ទាត់ ដែលមានការចូលរួមយ៉ាងច្រើនពីយុវជន និងបានជូនពរលើកទឹកចិត្ត និងសង្ឃឹមថា កីឡាករ-កីឡាការិនីកម្ពុជា នឹងទទួលបានលទ្ធផលល្អនៅក្នុងការប្រកួតកីឡាស៊ីហ្គេម លើកទី២៨ នៅក្នុងប្រទេសសិង្ហបុរី។

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅវេលាម៉ោង ១២ និង ៣០នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥